## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិ**
**ទទួលបន្ទុកកិច្ចការព្រំដែន**

លេខ......៣៦ សរណស........

# សេចក្តីប្រកាសបដិសេធព័ត៌មាន

តបទៅនឹងការផ្សាយព័ត៌មានតាមគេហទំព័ររបស់វិទ្យុអាស៊ីសេរីជាភាសាខ្មែរ (RFA Khmer) កាលពីថ្ងៃទី**២៦** ខែ**សីហា** ឆ្នាំ**២០២៣** ក្រោមចំណងជើងថា ***«ពលរដ្ឋសោកស្តាយព្រែកមួយដែលខ្មែរក្រហមជីក បាត់បង់ទៅវៀតណាមក្រោយបោះបង្គោលព្រំដែន»*** **លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន** សូមប្រកាសបដិសេធនិងច្រានចោលទាំងស្រុង និងសម្តែងការសោកស្តាយជាទីបំផុតចំពោះការផ្សព្វផ្សាយព័ត៌មានមិនពិត គ្មានមូលដ្ឋាន ខ្វះការយល់ដឹង ធ្វើឡើងក្នុងចេតនាទុច្ចរិត និងបំភាន់សាធារណជនជាតិនិងអន្តរជាតិ។

**លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន** សូមធ្វើការបំភ្លឺនិងបញ្ជាក់ជូនសាធារណជនជាតិ-អន្តរជាតិ និងជនរួមជាតិទាំងក្នុងនិងក្រៅប្រទេស ដូចខាងក្រោម៖

១. ព្រែកមួយខ្សែដែលវិទ្យុអាស៊ីសេរីបានលើកឡើងក្នុងគេហទំព័ររបស់ខ្លួននោះ មានឈ្មោះថា **«ព្រែកកំពង់ស្វាយ»** គឺជាព្រែកដែលមានបង្ហាញនៅលើផែនទីបោនខ្នាត ១/១០០ ០០០ របស់ក្រុមភូមិសាស្ត្រឥណ្ឌូចិន ដែលមានទីតាំងភូមិសាស្ត្រស្ថិតនៅតាមបណ្តោយខ្សែបន្ទាត់ព្រំដែនក្នុងស្រុកស្វាយជ្រំ ខេត្តស្វាយរៀង។ ផ្អែកតាមផែនទីបោននេះ ខ្សែព្រំដែនដើរតាមច្រាំងព្រែកខាងកម្ពុជា ប៉ុន្តែរាជរដ្ឋាភិបាលបានខិតខំចរចាយ៉ាងស្វិតស្វាញជាមួយភាគីវៀតណាមរហូតសម្រេចបានខ្សែព្រំដែនដើរតាមពាក់កណ្តាលព្រែកវិញ (បន្ទាត់ទ្រូងនៃផ្លូវទឹក) ស្របតាមគោលការណ៍ច្បាប់និងការអនុវត្តអន្តរជាតិ ដូចមានចែងក្នុងប្រការ១នៃសន្ធិសញ្ញាបំពេញបន្ថែមឆ្នាំ២០០៥ ដែលផ្តល់ផលប្រយោជន៍យ៉ាងធំធេងដល់ប្រជាពលរដ្ឋរស់នៅតាមបណ្តោយព្រែកមានសិទ្ធិពេញលេញក្នុងការប្រើប្រាស់ទឹក ការធ្វើនាវាចរណ៍ និងការនេសាទជាដើម។ល។

២. បង្គោលព្រំដែនបំពេញបន្ថែមលេខ229/11(1) ដែលវិទ្យុអាស៊ីសេរីបានលើកឡើងនោះ ជាបង្គោលមួយក្នុងចំណោមបង្គោលទាំងបីដែលត្រូវបោះនៅចំណុចផ្លូវទឹកបែកជាបី (បង្គោលត្រី) ក្នុងនោះបង្គោលលេខ229/11(1) បានបោះនៅច្រាំងព្រែកខាងកម្ពុជា ចំណែកឯបង្គោលលេខ229/11(2) និង 229/11(3) បានបោះនៅច្រាំងព្រែកខាងវៀតណាម ដូចមានបង្ហាញ

លើផែនទីភ្ជាប់ជូនមកជាមួយ។ **សូមបញ្ជាក់ជូនបន្ថែមថា** ទោះបីជាបង្គោលទាំងបីត្រូវបានបោះនៅលើច្រាំងព្រែកនៃភាគីទាំងពីរក៏ដោយ ក៏ខ្សែបន្ទាត់ព្រំដែនដើរតាមពាក់កណ្ដាលព្រែកកំពង់ស្នាយដដែល។

៣. ដូចគ្នានេះដែរ ចំពោះបង្គោលព្រំដែនបំពេញបន្ថែមលេខ229/10(1) គឺជាបង្គោលមួយក្នុងចំណោមបង្គោលពីរ(បង្គោលភ្លោះ) ដែលត្រូវបោះនៅសងខាងច្រាំងព្រែកកំពង់ស្នាយ ក្នុងនោះបង្គោលលេខ229/10(1) បានបោះនៅច្រាំងព្រែកខាងកម្ពុជា ចំណែកឯបង្គោលលេខ229/10(2) បានបោះនៅច្រាំងព្រែកខាងវៀតណាម ដូចមានបង្ហាញលើផែនទីភ្ជាប់ជូនមកជាមួយ។ **សូមបញ្ជាក់ជូនបន្ថែមថា** ទោះបីជាបង្គោលទាំងពីរត្រូវបានបោះនៅលើច្រាំងទាំងសងខាងព្រែកក៏ដោយ ក៏ខ្សែបន្ទាត់ព្រំដែនដើរតាមពាក់កណ្ដាលព្រែកកំពង់ស្នាយដដែល។

ជាថ្មីម្ដងទៀត ផ្អែកតាមមូលដ្ឋានផ្លូវច្បាប់និងមូលដ្ឋានបច្ចេកទេសដូចបានបញ្ជាក់ជូនខាងលើ **លេខាធិការដ្ឋានអចិន្ត្រៃយ៍នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន** សូមប្រកាសបដិសេធចោលទាំងស្រុង ចំពោះព័ត៌មានមិនពិត ក្លែងក្លាយ ដែលបានផ្សព្វផ្សាយដោយវិទ្យុអាស៊ីសេរី និងអំពាវនាវដល់សាធារណជនជាតិ-អន្តរជាតិនិងជនរួមជាតិទាំងអស់កុំជឿនិងកុំចែកចាយព័ត៌មានក្លែងក្លាយទាំងនេះ ព្រមទាំងលើកទឹកចិត្តឱ្យមានការផ្សព្វផ្សាយនិងចែកចាយសេចក្ដីបំភ្លឺនេះ ឱ្យបានទូលំទូលាយ ដើម្បីឱ្យមហាជនបានយល់ជ្រួតជ្រាបអំពីការពិតលើបញ្ហានេះ៕

ថ្ងៃអាទិត្យ ១១កើត ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២៣

**លេខាធិការដ្ឋានអចិន្ត្រៃយ៍**
**នៃអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន**

## ផែនទីបោន ខ្នាត ១/១០០០០០ បង្ហាញពីកំណាត់ខ្សែព្រំដែននៅតាមព្រែកកំពង់ស្វាយ

ស្ថិតក្នុងភូមិសាស្រ្ត ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង



## ផែនទីព្រំដែនបង្ហាញទីតាំងបង្គោលព្រំដែនបំពេញបន្ថែមលេខ 229/10( 1 ) និងលេខ 229/11( 1 )

ស្ថិតក្នុង ឃុំគ្រួស ស្រុកស្វាយជ្រំ ខេត្តស្វាយរៀង

